**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

អនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩
ជូនមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្នាក់ដឹកនាំ
អង្គការវិជ្ជាជីវៈ កម្មករនិយោជិតតាមរោងចក្រ សហគ្រាស និងកម្មករ
សេដ្ឋកិច្ចក្រៅប្រព័ន្ធ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូសទី១ និងដូសទី២ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ

អនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ សូមជម្រាបជូន សាធារណជន អំពីលទ្ធផលការចាក់វ៉ាក់សាំងកូវីដ-១៩ (ស៊ីណូវ៉ាក់) ដូសទី១ និងដូសទី២ ជូនបងប្អូនកម្មករនិយោជិត និងថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ ចាប់ពីថ្ងៃទី៧ ខែមេសា ដល់ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ ដូចខាងក្រោម៖

**ក-ការចាក់វ៉ាក់សាំងដូសទី១**

- **លទ្ធផលក្នុងថ្ងៃទី៣ ខែឧសភា**
  - អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងសរុបចំនួន ៣៦៩នាក់ (បរទេសចំនួន ៨នាក់)
  - ចាក់បានចំនួន ៣៦០នាក់ (បរទេសចំនួន ៨នាក់)
  - គ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់ចំនួន ៩នាក់ (បរទេសចំនួន ០នាក់)
- **លទ្ធផលគិតត្រឹមថ្ងៃនេះ**
  - អ្នកស្ម័គ្រចិត្តចាក់វ៉ាក់សាំងសរុបចំនួន ១២៦ ២៣៨នាក់ (បរទេសចំនួន ៣ ៩៩៦នាក់)
  - ចាក់បានចំនួន ១២៣ ០១១នាក់ (បរទេសចំនួន ៣ ៩៧៥នាក់)
  - គ្រូពេទ្យមិនអនុញ្ញាតឱ្យចាក់ចំនួន ៣ ២២៧នាក់ (បរទេសចំនួន ២១នាក់)

**ខ-ការចាក់វ៉ាក់សាំងដូសទី២**

- **លទ្ធផលក្នុងថ្ងៃទី៣ ខែឧសភា**
  - ចាក់បានចំនួន ៣ ២៤១នាក់ (បរទេសចំនួន ២៤៩នាក់)
- **លទ្ធផលគិតត្រឹមថ្ងៃនេះ**
  - ចាក់បានចំនួន ៥៣ ៩១១នាក់ (បរទេសចំនួន ១ ៩៣០នាក់)

អនុគណៈកម្មការចំពោះកិច្ច នឹងបន្តរៀបចំទីតាំងចាក់វ៉ាក់សាំងជូនបងប្អូនកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស ជាបន្តបន្ទាប់ទៀត។

អាស្រ័យហេតុនេះ សូម សាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ៧រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១